**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ០៧ សសរ

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតគណៈកម្មការស្រាវជ្រាវហេតុការណ៍ដែលនាំឲ្យកើតមានអំពើហិង្សា នៅតំបន់ផ្លូវវេងស្រេង រាជធានីភ្នំពេញ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ២០១៣ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើប្រាស់ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ ១.-**

បង្កើតគណៈកម្មការស្រាវជ្រាវស៊ើបបញ្ជាក់ហេតុការណ៍ដែលនាំឲ្យកើតមានអំពើហិង្សានៅតំបន់ផ្លូវវេងស្រេង រាជធានីភ្នំពេញ ដែលមានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| ១- ឯកឧត្តម នាយឧត្តមសេនីយ៍ នេត សាវឿន អគ្គស្នងការនគរបាលជាតិ | ប្រធាន |
| ២- ឯកឧត្តម នាយឧត្តមសេនីយ៍ សៅ សុខា មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស | អនុប្រធាន |
| ៣- តំណាងក្រសួងយុត្តិធម៌ | សមាជិក |
| ៤- អភិបាលរងនៃគណៈអភិបាលរាជធានីភ្នំពេញ | សមាជិក |

www.pheakdeylaw.com

**ប្រការ ២.-**

គណៈកម្មការនេះមានភារកិច្ច ដូចខាងក្រោម៖

- ចុះស្រាវជ្រាវស៊ើបបញ្ជាក់ហេតុការណ៍ដែលនាំឲ្យកើតមានអំពើហិង្សានៅតំបន់ផ្លូវវេងស្រេង រាជធានីភ្នំពេញ កាលពីថ្ងៃទី ០២ ខែមករា ឆ្នាំ២០១៤ ។
  មែប្រមូលឯកសារ ភស្តុតាង និងសាក្សី ដើម្បីរៀបចំបម្រើវិធានការច្បាប់ ។
- ..យការណ៍ និងសុំយោបល់ផ្ទាល់ពី ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ក្នុងពេលបំពេញភារកិច្ច ។
- ធ្វើរបាយការណ៍បូកសរុបលទ្ធផល និងផ្ដើមឡើងនូវវិធានការជូនរាជរដ្ឋាភិបាលពិនិត្យសម្រេច ។

**ប្រការ ៣.-**

គណៈកម្មការនេះមានសិទ្ធិប្រើប្រាស់មន្ត្រីជំនាញក្រោមឱវាទជាជំនួយការ ។

**ប្រការ ៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ អភិបាលរាជធានីភ្នំពេញ និងប្រធានស្ថាប័នដែលពាក់ព័ន្ធ ត្រូវអនុវត្តតាមសេចក្ដីសម្រេចនេះឲ្យទទួលបានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ៕

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែមករា ឆ្នាំ២០១៤

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**<u>កន្លែងទទួល៖</u>**

- ក្រសួងព្រះបរមរាជវាំង
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៤
- ឯកសារកាលប្បវត្តិ



www.pheakdeylaw.com